មជ្ឈមណ្ឌលជាតិនៃជនពិការ
National Centre of Disabled Persons
No.3, Norodom Blvd., Phnom Penh, Cambodia. P.O Box: 170
*Tel: (855-23) 210140 ; Fax: (855-23)213876*
*E-mail: ncdp_cambodia@online.com.kh*
*Web site: http://www.ncdpcam.org*

**យោង:**

**១.** លក្ខន្តិកៈ របស់មជ្ឈមណ្ឌលជាតិនៃជនពិការ

**២.** ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ របស់ មជ្ឈមណ្ឌលជាតិនៃជនពិការ (មជជព) ២០០៨-២០១២ ដើម្បីបំរើសេវាកម្មជូនជនពិការ

**៣.** ស្មារតីអង្គប្រជុំគណៈគ្រប់គ្រង មជជព នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩ បានសំរេច បង្កើតឱ្យមាន គណៈកម្មាធិការរៃអង្គាសមូលនិធិសំរាប់ មជជព ។

## គណៈកម្មធិការសម្រេចបង្កើតគោលការណ៍ដូចខាងក្រោម:

## គោលការណ៍

## រៃអង្គាសមូលនិធិ មជជព

### ១. គោលបំណង

ប្រមូលមូលនិធិដើម្បីទ្រទ្រង់សកម្មភាពកម្មវិធីរបស់ មជជព ដែលបាននឹងកំពុងតែប្រតិបត្តិការ ជួយដល់ជនពិការនៅទូទាំងប្រទេស ។ មជជព មាន ទស្សនៈវិស័យ បេសកកម្ម និងទិសដៅ ដូចខាងក្រោម:

- **ទស្សនៈវិស័យ**

មជជព ចង់ឃើញជនពិការមានការចូលរួមពេញលេញ និង អភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនលើគ្រប់វិស័យ ក្នុងសង្គមកម្ពុជា ។

- **បេសកកម្ម**

មជជព ផ្តល់នូវសេវា និង ឱកាសសំរាប់ជនពិការ ក្នុងការចូលរួមពេញលេញដោយប្រើប្រាស់ សិទ្ធិ និង សមត្ថភាពរបស់ខ្លួនក្នុងសកម្មភាព សង្គម សេដ្ឋកិច្ច និង នយោបាយអភិវឌ្ឍន៍ ។

- **ទិសដៅ**

ជនពិការទទួលបាននូវ សិទ្ធិ សេវាពតិមាន សុខភាព ស្តារលទ្ធភាព អប់រំ បណ្តុះបណ្តាលជំនាញ ការងារ និង ឱកាសរកប្រាក់ចំណូល ដើម្បីមានស្ថានភាពរស់នៅសមរម្យ មានការចូលរួមពេញលេញ និងជំរើសសកម្មភាពក្នុងសង្គម និង នយោបាយ ហើយក្លាយខ្លួនជាធនធានមនុស្សដ៏សំខាន់ សំរាប់សង្គមកម្ពុជា ។

ដើម្បីសំរេច ទស្សនៈវិស័យ បេសកកម្ម និងទិសដៅ មជជព បានបង្កើតកម្មវិធីជាច្រើនមកទល់បច្ចុប្បន្ន រួមមានដូចខាងក្រោម:

១. ***កម្មវិធីសេវាពត៌មាននិងទំនាក់ទំនង:*** កម្មវិធីនេះមានសកម្មភាព បញ្ជូនជនពិការទៅរកសេវាស្តារលទ្ធភាពពលកម្ម, ទទួលជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ, ជំនាញរកការងារធ្វើ, ជំនាញក្នុងការបង្កើតមុខរបរខ្នាតតូច, សិក្សាបន្តនៅថ្នាក់ឧត្តមសិក្សា, ការពិគ្រោះយោបល់ការងារ, វេទិកាពិភាក្សាបញ្ហាការងារ និងពិសេសស្វែងរកការងារជូនជនពិការ ។

២. ***កម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍:*** កម្មវិធីនេះផ្តល់សេវាកម្មគ្រប់ប្រភេទទៅតាមតំរូវការរបស់ជនពិការ តាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍ ដែលបង្កើតឡើងដោយ មជជព ក្នុងគោលបំណង ដើម្បីឱ្យមាននិរន្តរភាពសេវាកម្មសម្រាប់ជនពិការនៅក្នុងសហគមន៍ ដូចជា: ពិគ្រោះយោបល់ជាមួយគ្រួសារជនពិការ, បញ្ជូនជនពិការទៅមន្ទីរពេទ្យ និងមណ្ឌលស្តារ, ផ្តល់ឯកសណ្ឋាន និងសំភារៈសិក្សាដល់កុមារពិការ និងកូនជនពិការបានចូលសាលារៀន, ជួសជុលផ្ទះ, ផ្តល់ជាមុខរបរខ្នាតតូចដល់គ្រួសារជនពិការ ដើម្បីធានាជីវភាពសមរម្យ, សាងសង់បន្ទប់អនាម័យពិសេស, ជំរាល ដើម្បីសំរួលការបំលាស់ទីនៅតាមផ្ទះជនពិការ និងទីសាធារណៈក្នុងសហគមន៍ ។

៣. ***គ្រោងការហាងលក់សម្ភារ:*** គ្រោងការនេះមានសកម្មភាព បណ្តុះបណ្តាលជំនាញដូចជា ធ្វើខ្សែក្រវ៉ាត់ក, ធ្វើបណ្តោងសោរ, កាត់ដេរកាបូបធ្វើពីសូត្រ, និងផលិតផលធ្វើអំពីសូត្រផ្សេងៗទៀត ជាពិសេស ជួយរកទីផ្សារ និងជាកន្លែងតាំងលក់ផលិតផលជនពិការ ដើម្បីឱ្យជនពិការមានលទ្ធភាពចិញ្ចឹមខ្លួនឯង និងគ្រួសារ ។

៤. ***កម្មវិធីបណ្តុះបណ្តាល និងពត៌មានដើម្បីអភិវឌ្ឍន៍មុខរបរ:*** កម្មវិធី មានផ្តល់សេវាកម្មគ្រប់ប្រភេទដល់ជនពិការទាំងពីរភេទ ពិសេសជនពិការរងគ្រោះដោយសារមីន។ សកម្មភាពចំបងៗរបស់កម្មវិធីមាន ការអប់រំ, ផ្សព្វផ្សាយ, បណ្តុះបណ្តាលជំនាញពេទ្យសត្វ, ធ្វើជីកំប៉ុស, ដំណាំលក្ខណៈគ្រួសារ, ស្តារលទ្ធភាពពលកម្ម, បង្កើតមុខរបរខ្នាតតូចជាលក្ខណៈឯកត្តបុគ្គល និងក្រុម ទៅដល់ជនពិការក្នុងតំបន់តាមរយៈក្រុមជួយខ្លួនឯង ។

៥. ***គ្រោងការសេវាសង្គមជួយជនរងគ្រោះដោយសារគ្រាប់មីន:*** កម្មវិធីនេះ ផ្តល់សេវាកម្មសង្គ្រោះបន្ទាន់, បញ្ជូនជនពិការទៅមន្ទីរពេទ្យ, ផ្តល់មុខរបរខ្នាតតូច, ផ្តល់ទីជំរកសមរម្យ, បញ្ជូនទៅយកជើង-ដៃសិប្បនិម្មិត, ផ្តល់វ៉ែនតាសម្រាប់ជនពិការភ្នែក, បញ្ជូនទៅរកសេវាកម្មវះកាត់ភ្នែក, និងសេវាកម្មផ្សេងៗទៀត ដល់ជនពិការដោយសារមីន ។

៦. ***គ្រោងការវេទិកាជនពិការ*** : គ្រោងការនេះ រៀបចំឡើងដើម្បីផ្សព្វផ្សាយអំពីវិស័យពិការភាពពិសេស ប្រភេទពិការទាំងប្រាំបី, ការទប់ស្កាត់ពិការភាព តាមរយៈការអញ្ជើញវាគ្មិនចូលរួមក្នុងវេទិកាដើម្បីពិភាក្សាអំពីបញ្ហាពិការភាព, ជំរុញចលនាពិការក្នុងឆាកជាតិ និងអន្តរជាតិ ដោយមានការចាក់ផ្សព្វផ្សាយតាមរយៈ វិទ្យុ, ទូរទស្សន៍, ការសែត និងឧបករណ៍ផ្សព្វផ្សាយផ្សេងៗទៀត ។

មូលនិធិនេះក៏មានបំណងជួយដល់អង្គការជនពិការផ្សេងៗទៀតដែរ ពិសេសអង្គការជនពិការដែលនៅតាមសហគមន៍ ក្នុងករណីដែលថវិកាវែរអង្គាសនេះអាចមានលទ្ធភាព និងមានចំនួនច្រើន។

## ៤. ទំរង់នៃការរៃអង្គាស

មូលនិធិ មជជព និងរៀបចំវិធីសាស្ត្រច្រើនយ៉ាងដើម្បីធ្វើការរៃអង្គាសថវិកាដែលក្នុងនោះរួមមានដូចជា:

២.១. ការទទួលទានអាហារវិភាគទាន

២.២. ការបង្កើតប័ណ្ណមូលនិធិ

២.៣. ការរៃអង្គាសជាលក្ខណៈ សមាជិក ឯកត្តបុគ្គល និងសប្បុរសជន

២.៤. ការរៃអង្គាសតាមរយៈការដាក់ប្រអប់មូលនិធិ

២.៥. ការឧត្ថម្ភពី សមាជិកកិត្តិយស ក្រុមហ៊ុន និងស្ថាប័ននានា ទាំងក្នុង និងក្រៅប្រទេស

២.៦. ការរៃអង្គាសតាមរយៈ សហគមន៍ម្ចាស់ជំនួយដោយ មជជព និងរដ្ឋាភិបាល

## ៥. ការគ្រប់គ្រង និងការចាត់ចែងមូលនិធិ

ដើម្បីឱ្យមានតម្លាភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រង និងចាត់ចែង មូលនិធិដែលទទួលបានតាមរយៈទំរង់នៃការរៃអង្គាសមូលនិធិខាងលើ មជជព អនុវត្តដូចខាងក្រោម :

- ការប្រើប្រាស់មូលនិធិ ត្រូវគោរពទៅតាម នីតិវិធីគោលការណ៍ហិរញ្ញវត្ថុ របស់មជជព ។
- គោរពទៅតាមលក្ខន្តិកៈ និងសេចក្តីស្នើសុំរបស់ អ្នកផ្តល់ជំនួយ។
- ផ្តល់ជូនសេវាកម្ម និងជាមូលនិធិដល់ដៃជនពិការ តាមការស្នើសុំរបស់អ្នកផ្តល់ជំនួយ ក្នុងករណីចាំបាច់ណាមួយ។
- ម្ចាស់ជំនួយមានសិទ្ធិស្នើសុំរបាយការណ៍ និងទទួលវិក័យប័ត្រតាមគោលការណ៍ហិរញ្ញវត្ថុ។
- របាយការណ៍ចំណូល និង ចំណាយនឹងត្រូវបានរាយការណ៍ និងធ្វើសវនកម្ម ដោយសវនករ មកពីក្រុមហ៊ុនជំនាញដោយគោរពតាមបទដ្ឋានជាតិ និងអន្តរជាតិ។

## ៦. ការលើកទឹកចិត្ត

- ម្ចាស់ជំនួយ និងអ្នកឧបត្ថម្ភជា សមាជិក, ឯកត្តបុគ្គល, សប្បុរសជន និងក្រុមហ៊ុនឯកជន ទទួលបាននូវការផ្សព្វផ្សាយ ផ្លាកសញ្ញា, ឈ្មោះ, ផលិតផល, តាមរយៈ ខិតប័ណ្ណ លិខិតផ្សព្វផ្សាយ, វិទ្យុ, ទូរទស្សន៍, កាសែត និងទស្សនាវដ្តី។
- មជជព នឹងផ្តល់ជូនដល់សប្បុរសជនទាំងក្នុង និងក្រៅប្រទេសដូចខាងក្រោម:
  - លិខិតថ្លែងអំណរគុណ
  - ប័ណ្ណសរសើរ

- មេដាយកិត្តិយស សិរិទ្ធ, ប្រាក់ និងមាស
- ចូលរួមក្នុងព្រឹត្តការណ៍សំខាន់ៗរបស់ មជជព

## ៧. ការចូលជាធរមាន

គោលការណ៍វែអង្គាសមូលនិធិ នេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មាធិការ និងជានាយកប្រតិបត្តិ និង ប្រថាប់ត្រា មជជព ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០

**ប្រធានគណៈកម្មាធិការ និងនាយកប្រតិបត្តិ**

**យី ទាសនា**